# C182 - Worst Forms of Child Labour Convention, 1999 (No. 182)

*Convention concerning the Prohibition and Immediate Action for the Elimination of the Worst Forms of Child Labour (Entry into force: 19 Nov 2000)Adoption: Geneva, 87th ILC session (17 Jun 1999) - Status: Up-to-date instrument (Fundamental Convention).*

## Preamble

The General Conference of the International Labour Organization,

Having been convened at Geneva by the Governing Body of the International Labour Office, and having met in its 87th Session on 1 June 1999, and

Considering the need to adopt new instruments for the prohibition and elimination of the worst forms of child labour, as the main priority for national and international action, including international cooperation and assistance, to complement the Convention and the Recommendation concerning Minimum Age for Admission to Employment, 1973, which remain fundamental instruments on child labour, and

Considering that the effective elimination of the worst forms of child labour requires immediate and comprehensive action, taking into account the importance of free basic education and the need to remove the children concerned from all such work and to provide for their rehabilitation and social integration while addressing the needs of their families, and

Recalling the resolution concerning the elimination of child labour adopted by the International Labour Conference at its 83rd Session in 1996, and

Recognizing that child labour is to a great extent caused by poverty and that the long-term solution lies in sustained economic growth leading to social progress, in particular poverty alleviation and universal education, and

Recalling the Convention on the Rights of the Child adopted by the United Nations General Assembly on 20 November 1989, and

Recalling the ILO Declaration on Fundamental Principles and Rights at Work and its Follow-up, adopted by the International Labour Conference at its 86th Session in 1998, and

Recalling that some of the worst forms of child labour are covered by other international instruments, in particular the Forced Labour Convention, 1930, and the United Nations Supplementary Convention on the Abolition of Slavery, the Slave Trade, and Institutions and Practices Similar to Slavery, 1956, and

Having decided upon the adoption of certain proposals with regard to child labour, which is the fourth item on the agenda of the session, and

Having determined that these proposals shall take the form of an international Convention;

adopts this seventeenth day of June of the year one thousand nine hundred and ninety-nine the following Convention, which may be cited as the Worst Forms of Child Labour Convention, 1999.

## Article 1

Each Member which ratifies this Convention shall take immediate and effective measures to secure the prohibition and elimination of the worst forms of child labour as a matter of urgency.

## Article 2

For the purposes of this Convention, the term **child** shall apply to all persons under the age of 18.

### *Article 3*

For the purposes of this Convention, the term **the worst forms of child labour** comprises:

- (a) all forms of slavery or practices similar to slavery, such as the sale and trafficking of children, debt bondage and serfdom and forced or compulsory labour, including forced or compulsory recruitment of children for use in armed conflict;
- (b) the use, procuring or offering of a child for prostitution, for the production of pornography or for pornographic performances;
- (c) the use, procuring or offering of a child for illicit activities, in particular for the production and trafficking of drugs as defined in the relevant international treaties;
- (d) work which, by its nature or the circumstances in which it is carried out, is likely to harm the health, safety or morals of children.

### *Article 4*

1. The types of work referred to under Article 3(d) shall be determined by national laws or regulations or by the competent authority, after consultation with the organizations of employers and workers concerned, taking into consideration relevant international standards, in particular Paragraphs 3 and 4 of the Worst Forms of Child Labour Recommendation, 1999.

2. The competent authority, after consultation with the organizations of employers and workers concerned, shall identify where the types of work so determined exist.

3. The list of the types of work determined under paragraph 1 of this Article shall be periodically examined and revised as necessary, in consultation with the organizations of employers and workers concerned.

### *Article 5*

Each Member shall, after consultation with employers' and workers' organizations, establish or designate appropriate mechanisms to monitor the implementation of the provisions giving effect to this Convention.

### *Article 6*

1. Each Member shall design and implement programmes of action to eliminate as a priority the worst forms of child labour.

2. Such programmes of action shall be designed and implemented in consultation with relevant government institutions and employers' and workers' organizations, taking into consideration the views of other concerned groups as appropriate.

### *Article 7*

1. Each Member shall take all necessary measures to ensure the effective implementation and enforcement of the provisions giving effect to this Convention including the provision and application of penal sanctions or, as appropriate, other sanctions.

2. Each Member shall, taking into account the importance of education in eliminating child labour, take effective and time-bound measures to:

- (a) prevent the engagement of children in the worst forms of child labour;
- (b) provide the necessary and appropriate direct assistance for the removal of children from the worst forms of child labour and for their rehabilitation and social integration;
- (c) ensure access to free basic education, and, wherever possible and appropriate, vocational training, for all children removed from the worst forms of child labour;
- (d) identify and reach out to children at special risk; and
- (e) take account of the special situation of girls.

3. Each Member shall designate the competent authority responsible for the implementation of the provisions giving effect to this Convention.

## Article 8

Members shall take appropriate steps to assist one another in giving effect to the provisions of this Convention through enhanced international cooperation and/or assistance including support for social and economic development, poverty eradication programmes and universal education.

## Article 9

The formal ratifications of this Convention shall be communicated to the Director-General of the International Labour Office for registration.

## Article 10

1. This Convention shall be binding only upon those Members of the International Labour Organization whose ratifications have been registered with the Director-General of the International Labour Office.

2. It shall come into force 12 months after the date on which the ratifications of two Members have been registered with the Director-General.

3. Thereafter, this Convention shall come into force for any Member 12 months after the date on which its ratification has been registered.

## Article 11

1. A Member which has ratified this Convention may denounce it after the expiration of ten years from the date on which the Convention first comes into force, by an act communicated to the Director-General of the International Labour Office for registration. Such denunciation shall not take effect until one year after the date on which it is registered.

2. Each Member which has ratified this Convention and which does not, within the year following the expiration of the period of ten years mentioned in the preceding paragraph, exercise the right of denunciation provided for in this Article, will be bound for another period of ten years and, thereafter, may denounce this Convention at the expiration of each period of ten years under the terms provided for in this Article.

## Article 12

1. The Director-General of the International Labour Office shall notify all Members of the International Labour Organization of the registration of all ratifications and acts of denunciation communicated by the Members of the Organization.

2. When notifying the Members of the Organization of the registration of the second ratification, the Director-General shall draw the attention of the Members of the Organization to the date upon which the Convention shall come into force.

## Article 13

The Director-General of the International Labour Office shall communicate to the Secretary-General of the United Nations, for registration in accordance with article 102 of the Charter of the United Nations, full particulars of all ratifications and acts of denunciation registered by the Director-General in accordance with the provisions of the preceding Articles.

## Article 14

At such times as it may consider necessary, the Governing Body of the International Labour Office shall present to the General Conference a report on the working of this Convention and shall examine the desirability of placing on the agenda of the Conference the question of its revision in whole or in part.

## Article 15

1. Should the Conference adopt a new Convention revising this Convention in whole or in part, then, unless the new Convention otherwise provides --

- (a) the ratification by a Member of the new revising Convention shall ipso jure involve the immediate denunciation of this Convention, notwithstanding the provisions of Article 11 above, if and when the new revising Convention shall have come into force;

- (b) as from the date when the new revising Convention comes into force, this Convention shall cease to be open to ratification by the Members.

2. This Convention shall in any case remain in force in its actual form and content for those Members which have ratified it but have not ratified the revising Convention.

### [illegible]

The English and French versions of the text of this Convention are equally authoritative.

# អនុសញ្ញាលេខ ១៨២
# ស្តីពី
# អនុសញ្ញាស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

## មហាសន្និបាតអង្គការអន្តរជាតិខាងការងារ

-ដោយបានកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និងដោយបានរួមប្រជុំនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ១៩៩៩ ក្នុងសម័យប្រជុំលើកទី ៨៧ និង

-ដោយយល់ឃើញថា ដល់ពេលអនុម័តឯកសារឧបករណ៍ថ្មីសម្រាប់ការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធិភាព ដែលជាអាទិភាពចំបងសម្រាប់សកម្មភាពជាតិ និងអន្តរជាតិ រួមមាន កិច្ចសហប្រតិបត្តិការ និងជំនួយឧបត្ថម្ភជាអន្តរជាតិ និងដើម្បីបំពេញបន្ថែមនូវអនុសញ្ញា និងអនុសាសន៍ស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការងារឆ្នាំ១៩៧៣ ដែលនៅតែជាឧបករណ៍គ្រឹះពលកម្មកុមារ និង

-ដោយយល់ឃើញថា ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធិភាព តម្រូវឱ្យមាននូវសកម្មភាពជាបន្ទាន់ និងទូលំទូលាយដែលនឹងយកចិត្តទុកដាក់នូវសារៈសំខាន់នៃការអប់រំជាមូលដ្ឋានដោយឥតបង់ថ្លៃ និងសេចក្តីត្រូវការដើម្បីដកយកកុមារពាក់ព័ន្ធចេញពីកន្លែងធ្វើការងារ និងដើម្បីផ្តល់ឱ្យពួកគេនូវការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មទៅក្នុងសង្គម ខណៈដែលនឹងឆ្លើយតបនូវសេចក្តីត្រូវការនៃគ្រួសាររបស់គេ និង

-ដោយរំលឹកឡើងវិញនូវដំណោះស្រាយស្តីពីការលុបបំបាត់ពលកម្មកុមារត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិខាងការងារនៅសម័យប្រជុំលើកទី ៨៣ ក្នុងឆ្នាំ១៩៩៦ និង

-ដោយទទួលស្គាល់ថា ពលកម្មកុមារ គឺជាទំហំដ៏ធំធេងដែលបណ្តាលមកពីភាពក្រីក្រ និងជាដំណោះស្រាយយូរអង្វែងដែលពឹងផ្អែកទាំងស្រុងទៅលើការរីកលូតលាស់សេដ្ឋកិច្ចប្រកបដោយនិរន្តភាពដែលនាំដល់ការរីកចំរើនផ្នែកសង្គម ជាពិសេសការកាត់បន្ថយភាពក្រីក្រ និងការអប់រំជាសាកល និង

-ដោយរំលឹកឡើងវិញនូវអនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ និង

-ដោយរំលឹកឡើងវិញនូវសេចក្តីប្រកាសរបស់អង្គការអន្តរជាតិខាងការងារស្តីពីគោលការណ៍គ្រឹះ និងសិទ្ធិធ្វើការងារ និងការអនុវត្តន៍បន្តត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិខាងការងារក្នុងសម័យប្រជុំទី ៨៦ ក្នុងឆ្នាំ១៩៩៨ និង

-ដោយរំលឹងឡើងវិញនូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារមួយចំនួនត្រូវបានគ្របដណ្តប់ដោយបរិធានអន្តរជាតិផ្សេងៗទៀត ជាពិសេសអនុសញ្ញាស្តីពីការងារដោយបង្ខំនៅឆ្នាំ១៩៣០ និងអនុសញ្ញាបំពេញបន្ថែមរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ទាសភាពការធ្វើអាជីវកម្មទាសករ ព្រមទាំងការប្រព្រឹត្តនឹងការអនុវត្តន៍ប្រហាក់ប្រហែលទៅនឹងទាសភាពនៅឆ្នាំ១៩៥៦ និង

-ដោយបានសំរេចលើការអនុម័តនៃសំណើជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងពលកម្មកុមារដែលជារបៀបវារៈទី ៤ នៃសម័យប្រជុំ និង

-ដោយបានកំណត់ថា សំណើទាំងនេះនឹងរៀបចំជាទម្រង់បែបបទនៃអនុសញ្ញាអន្តរជាតិ សន្និសីទសំរេចអនុម័តនៅថ្ងៃទីដប់ប្រាំពីរ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំបួន នូវអនុសញ្ញាខាងក្រោមដែលមានឈ្មោះថា "អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ១៩៩៩"។

## មាត្រា ១

រដ្ឋជាសមាជិកនីមួយៗដែលផ្តល់សច្ចាប័នលើអនុសញ្ញានេះត្រូវចាត់វិធានការបន្ទាន់ និងមានប្រសិទ្ធិភាពដើម្បីធានាដល់ការហាមប្រាម និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលជាបញ្ហាបន្ទាន់។

## មាត្រា ២

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "កុមារ" ត្រូវអនុវត្តន៍ចំពោះមនុស្សគ្រប់រូបដែលមានអាយុក្រោម ១៨ឆ្នាំ។

## មាត្រា ៣

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ" រួមមាន៖

(ក) គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬការអនុវត្តន៍ប្រហាក់ប្រហែលទៅនឹងទាសភាព ដូចជាការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះគេដាច់ថ្លៃ ការងារដោយបង្ខំ ឬការងារដោយកាតព្វកិច្ច រួមទាំងការជ្រើសរើសកុមារដោយបង្ខំ ឬដោយកាតព្វកិច្ចដើម្បីឱ្យបំរើក្នុងជម្លោះប្រដាប់អាវុធ។

(ខ) ការប្រើប្រាស់ ការអូសទាញ ឬការផ្តល់ឱ្យកុមារបំរើក្នុងពេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសម្តែងអាសគ្រាម។

(គ) ការប្រើប្រាស់ ការអូសទាញ ឬផ្តល់ឱ្យកុមារបំរើក្នុងសកម្មភាពខុសច្បាប់ ជាពិសេសការផលិត និងការជួញដូរគ្រឿងញៀន ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានា។

(ឃ) ការងារទាំងឡាយណាដែលមានលក្ខណៈ ឬស្ថានភាពរបស់វានៅពេលដែលត្រូវបានគេអនុវត្តអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ។

## មាត្រា ៤

១. ប្រភេទនៃការងារដែលបានចែងក្នុងមាត្រា ៣ (ឃ) ត្រូវបានកំណត់ដោយច្បាប់ជាតិ ឬបទប្បញ្ញត្តិ ឬដោយអាជ្ញាធរមានសមត្ថកិច្ច ក្រោយពីបានប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធ ដោយយកចិត្តទុកដាក់ពិចារណាទៅលើបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេស វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃអនុសាសន៍ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ១៩៩៩។

២. ក្រោយពីបានប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធរួចមក អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ថាតើប្រភេទការងារណាត្រូវកំណត់ជាទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

៣. បញ្ជីនៃប្រភេទការងារដែលបានកំណត់នៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវពិនិត្យ និងកែសម្រួលឡើងវិញជាទៀតទាត់ ប្រសិនបើចាំបាច់ដោយប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធ។

## មាត្រា ៥

បន្ទាប់ពីប្រឹក្សាយោបល់ជាមួយអង្គការនិយោជក និងកម្មករនិយោជិត រដ្ឋជាសមាជិកនីមួយៗត្រូវបង្កើតឡើង ឬចាត់តាំងយន្តការដ៏សមស្របដើម្បីពិនិត្យតាមដានការអនុវត្តន៍នូវបទប្បញ្ញត្តិ ដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះ។

## [illegible]

១. រដ្ឋជាសមាជិកនីមួយៗត្រូវរៀបចំ និងអនុវត្តកម្មវិធីសកម្មភាពនានា ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលជាអាទិភាព។

២. កម្មវិធីសកម្មភាពទាំងនោះត្រូវបានរៀបចំ និងអនុវត្តដោយមានការប្រឹក្សាយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធអង្គការនិយោជក និងកម្មករនិយោជិតយកចិត្តទុកដាក់ពិចារណាលើទស្សនៈរបស់ក្រុមពាក់ព័ន្ធដទៃៗទៀតឱ្យបានសមស្រប។

## មាត្រា ៧

១. រដ្ឋជាសមាជិកនីមួយៗត្រូវចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាការអនុវត្តន៍បទប្បញ្ញត្តិនានា ដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះរួមទាំងបទប្បញ្ញត្តិ និងការអនុវត្តន៍ទោសព្រហ្មទណ្ឌ ឬទោសទណ្ឌកម្មផ្សេងៗទៀតឱ្យបានសមស្រប។

២. រដ្ឋជាសមាជិកនីមួយៗត្រូវយកចិត្តទុកដាក់លើសារៈសំខាន់នៃការអប់រំក្នុងការលុបបំបាត់ពលកម្មកុមារដោយប្រកាន់យកនូវវិធានការប្រកបដោយប្រសិទ្ធិភាព និងមានពេលវេលាកំណត់ដើម្បី៖

(ក) ទប់ស្កាត់នូវការចូលរួមរបស់កុមារនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតពលកម្មកុមារ។

(ខ) ផ្តល់ជំនួយឧបត្ថម្ភដោយផ្ទាល់ដែលចាំបាច់ និងសមស្របសម្រាប់ការដកហូតកុមារចេញពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងផ្តល់ការស្តារនីតិសម្បទាព្រមទាំងធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញ។

(គ) ធានាលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ ប្រសិននឹងបើអាចធ្វើទៅបាន គឺផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របសម្រាប់កុមារទាំងអស់ដែលបានដកចេញពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

(ឃ) កំណត់ និងចាត់វិធានការចំពោះកុមារងាយរងគ្រោះពិសេស និង

(ង) យកចិត្តទុកដាក់ចំពោះស្ថានភាពពិសេសរបស់កុមារី។

៣. ដ្ឋជាសមាជិកនីមួយៗត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចឱ្យទទួលខុសត្រូវចំពោះការអនុវត្តន៍បទប្បញ្ញត្តិដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះ។

## មាត្រា ៨

រដ្ឋជាសមាជិកទាំងឡាយត្រូវចាត់វិធានការសមស្របនានាដើម្បីជួយគ្នាទៅវិញទៅមកក្នុងការផ្តល់ប្រសិទ្ធិភាពដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះតាមរយៈការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬជំនួយឧបត្ថម្ភរួមទាំងការគាំទ្រសម្រាប់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច កម្មវិធីលុបបំបាត់ភាពក្រីក្រ និងការអប់រំជាសកល។

## មាត្រា ៩

ការផ្តល់សច្ចាប័នជាផ្លូវការលើអនុសញ្ញានេះ ត្រូវទំនាក់ទំនងជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារសម្រាប់កាចុះបញ្ជិកា។

## មាត្រា ១០

១. អនុសញ្ញានេះត្រូវចងភ្ជាប់តែទៅលើរដ្ឋជាសមាជិកនៃអង្គការអន្តរជាតិខាងការងារទាំងឡាយណាដែលការផ្តល់សច្ចាប័នត្រូវបានចុះបញ្ជិកាជាមួយអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារប៉ុណ្ណោះ។

២. អនុសញ្ញានេះនឹងចូលជាធរមានរយៈពេល ១២ ខែ ក្រោយកាលបរិច្ឆេទដែលការផ្តល់សច្ចាប័ននៃសមាជិកចំនួនពីរត្រូវបានចុះបញ្ជិកាជាមួយអគ្គនាយក។

៣. ក្រោយមក អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់រដ្ឋជាសមាជិកណាក៏ដោយរយៈពេល ១២ ខែ ក្រោយកាលបរិច្ឆេទដែលការផ្តល់សច្ចាប័នត្រូវបានចុះបញ្ជិកា។

## មាត្រា ១១

១. សមាជិកមួយ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយអាចបដិសេធវិញបន្ទាប់ពីការផុតកំណត់រយៈពេល ១០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានលើកដំបូងបង្អស់តាមរយៈបទប្បញ្ញត្តិដែលឱ្យដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារសម្រាប់ការចុះបញ្ជិកា។ សេចក្តីបដិសេធនេះនឹងមិនចូលជាធរមានរហូតរយៈពេល ១ឆ្នាំ ក្រោយកាលបរិច្ឆេទ ដែលអនុសញ្ញានេះត្រូវបានចុះបញ្ជិកា។

២. រដ្ឋជាសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយ ហើយដែលមិនបានអនុវត្តនូវសិទ្ធិបដិសេធដែលចែងនៅក្នុងមាត្រាក្នុងអំឡុងពេល ១ឆ្នាំ ដែលចែងនូវការផុតកំណត់នៃអំឡុងពេល ១០ឆ្នាំ ដូចមានចែងនៅក្នុងកថាខណ្ឌមុនៗ នឹងត្រូវលើកសិទ្ធិបដិសេធនេះសម្រាប់អំឡុងពេល ១០ឆ្នាំ ក្រោយទៀត ហើយបន្ទាប់មកទើបអាចមានសិទ្ធិបដិសេធអនុសញ្ញានេះនៅពេលផុតកំណត់នៃអំឡុងពេល ១០ឆ្នាំ ក្រោមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រានេះ។

## មាត្រា ១២

១. អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារនឹងជូនដំណឹងទៅគ្រប់រដ្ឋសមាជិកទាំងអស់នៃអង្គការអន្តរជាតិខាងការងារអំពីការចុះបញ្ជិកាលើរាល់ការផ្តល់សច្ចាប័ន និងបទប្បញ្ញត្តិបដិសេធដែលរដ្ឋសមាជិកនៃអង្គការនេះបានបញ្ជូនមកឱ្យខ្លួន។

២. នៅពេលជូនដំណឹងទៅឱ្យរដ្ឋសមាជិកនៃអង្គការនេះ អំពីការចុះបញ្ជិកានៃការផ្តល់សច្ចាប័នលើកទីពីរ អគ្គនាយកត្រូវទាក់ទាញចំណាប់អារម្មណ៍នៃរដ្ឋសមាជិកទាំងឡាយរបស់អង្គការនេះ ចំពោះកាលបរិច្ឆេទដែលអនុសញ្ញានឹងចូលជាធរមាន។

## មាត្រា ១៣

អគ្គនាយនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវផ្តល់ដំណឹងទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ សម្រាប់ការចុះបញ្ជិកាដោយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិនូវរាល់ចំណុចពិស្តារពេញលេញនៃការផ្តល់សច្ចាប័នទាំងអស់និងបទប្បញ្ញត្តិបដិសេធដែលចុះបញ្ជិកាដោយអគ្គនាយកដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាមុនៗ។

## មាត្រា ១៤

នៅក្នុងពេលវេលាមួយដែលយល់ថាចាំបាច់ ក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារត្រូវបង្ហាញជូនមហាសន្និបាតនូវរបាយការណ៍ស្តីពីការអនុវត្តន៍លើអនុសញ្ញានេះ ហើយត្រូវពិនិត្យមើលពីបំណងប្រាថ្នានៃការដាក់បញ្ចូលក្នុងរបៀបវារៈនៃសន្និសីទនូវសំណួរ នៃការកែប្រែអនុសញ្ញានេះទាំងមូល ឬមួយផ្នែក។

## មាត្រា ១៥

១. នៅក្នុងករណីដែលមហាសន្និបាតអនុម័តលើអនុសញ្ញាថ្មីមួយដែលកែប្រែអនុសញ្ញានេះទាំងមូល ឬដោយផ្នែក វៀរលែងតែអនុសញ្ញាថ្មីនេះមានចែងថា៖

(ក) ការផ្តល់សច្ចាប័នដោយរដ្ឋសមាជិកនៃអនុសញ្ញាកែប្រែថ្មីនឹងនាំទៅដល់ការបដិសេធអនុសញ្ញានេះភ្លាមដោយពេញច្បាប់ និងដោយមិនគិតទៅដល់បទប្បញ្ញត្តិនៃមាត្រា ១១ ខាងលើ ប្រសិនបើនិងនៅពេលដែលអនុសញ្ញាកែប្រែថ្មីនេះចូលជាធរមាន។

(ខ) ចាប់តាំងពីកាលបរិច្ឆេទដែលអនុសញ្ញាកែប្រែថ្មីចូលជាធរមានអនុសញ្ញានេះនឹងត្រូវបញ្ចប់ការបើកចំហចំពោះការផ្តល់សច្ចាប័នដោយរដ្ឋសមាជិក។

២. ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនឹងនៅជាធរមានដដែលទាំងទម្រង់និងខ្លឹមសារជាក់ស្តែងរបស់ខ្លួន សម្រាប់រដ្ឋសមាជិកទាំងឡាយណាដែលបានផ្តល់សច្ចាប័នលើអនុសញ្ញារួចហើយ ប៉ុន្តែមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាកែប្រែថ្មីឡើយ។

## មាត្រា ១៦

ទាំងអត្ថបទជាភាសាអង់គ្លេស និងបារាំងនៃអនុសញ្ញានេះ គឺមានតម្លៃស្មើគ្នា។

ចាប់តាំងពីពេលមុនៗមក គឺជាអត្ថបទដែលត្រឹមត្រូវតាមច្បាប់នៃអនុសញ្ញាត្រូវបានអនុម័តជាឯកច្ឆន្ទដោយមហាសន្និបាតនៃអង្គការអន្តរជាតិខាងការងារក្នុងសម័យប្រជុំលើកទី ៨៧ ដែលប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ និងបានប្រកាសបិទនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩។ យើងបានចុះហត្ថលេខារបស់យើងនៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ១៩៩៩។

********************